**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខៈ ៦០៤៩ ប្រក

# ប្រកាស
# ស្តីពី
# ការប្តូរឈ្មោះសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សមាគមសប្បុរសធម៌ សុក ស៊ីផាន់ណា & ខៀវ មាលី

## សម្រេច

**ប្រការ ១ ..**

ត្រូវបានប្តូរឈ្មោះ "សមាគមសប្បុរសធម៌ សុក ស៊ីផាន់ណា & ខៀវ មាលី" មកជាឈ្មោះ **សមាគមសុកខៀវ សមិទ្ធិដើម្បីសិល្បៈ** ក្នុងបញ្ជីសមាគម នៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋានទីស្នាក់ការកណ្តាលនៅភូមិលើ ឃុំព្រែក-អញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។

**ប្រការ ២ ..**

**សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣ ..**

ប្រកាសលេខ៨៨៨៧ ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ..**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ........ខែ........ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ខែ........ឆ្នាំ២០២៣

ឧ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ឌី.សុភផាន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ធនាគារជាតិ នៃកម្ពុជា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ខុទ្ទកាល័យឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  ( ដើម្បីជូនជ្រាប )
- ដូចប្រការ ៤ ( ដើម្បីអនុវត្ត )
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ
# សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ
# SOK KHIEU SAMITHI'S ART ASSOCIATION

## ជំពូកទី ១
## គោលបំណង និងគោលដៅ

### ប្រការ ១. អំពីគោលបំណង

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានគោលបំណងសំខាន់ៗដូចជា៖

- ចូលរួមសកម្មភាពផ្នែកសប្បុរសធម៌ក្នុងវិស័យអប់រំ សិល្បៈ និងវិទ្យាសាស្ត្រ
- ចូលរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជា ស្របតាមគោលនយោបាយបញ្ចកោណរបស់រដ្ឋាភិបាល ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការជួយទំនុកបំរុងកុមារឱ្យទទួលបានការសិក្សា ការផ្តល់ជាអាហារូបករណ៍ដល់យុវជន និងយុវនារីក្រីក្រ និងផ្តល់ឱកាសការងារនានា
- ជួយដល់សកម្មភាពនានាទាក់ទងនឹងការបណ្តុះបណ្តាល សិក្សា ស្រាវជ្រាវ និងការចងក្រងនូវកម្រងឯកសារនានាក្នុងវិស័យអប់រំ សិល្បៈ និងវិទ្យាសាស្ត្រ។

### ប្រការ ២. អំពីគោលដៅ

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានគោលដៅសំខាន់ៗដូចជា៖

- កសាងទំនាក់ទំនងជាមួយគ្រឹះស្ថានអប់រំរួមមាន៖ សាលារៀន សាកលវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ឱកាសដល់កុមារ យុវជន យុវនារីក្នុងការសិក្សាផ្នែកសិល្បៈដូចជា៖ ល្ខោន កុន ចម្រៀង គំនូរ វិទ្យាសាស្ត្រ ។ល។
- ស្វែងរកឱកាសជូនដល់អ្នកសិល្បៈ និងអ្នកវិទ្យាសាស្ត្រនានា ក្នុងការដាក់តាំងពិពណ៌បង្ហាញស្នាដៃដែលខ្លួនផលិតបាន ជូនសាធារណជនទាំងក្នុងប្រទេស និងក្រៅប្រទេស។

## ជំពូកទី ២
## ការកំណត់ឈ្មោះ ទីស្នាក់ការ អត្តសញ្ញាណ សញ្ញាសម្គាល់ និងត្រា

### ប្រការ ៣. អំពីការកំណត់ឈ្មោះ

សមាគមនេះមានឈ្មោះជាភាសាខ្មែរថា **សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ** សរសេរអក្សរកាត់ "**ស.ស.ស.ស.**" និងមានឈ្មោះជាភាសាអង់គ្លេសថា **SOK KHIEU SAMITHI'S ART ASSOCIATION** សរសេរជាអក្សរកាត់ថា "**S.K.S.A**"។

### ប្រការ ៤. អំពីទីស្នាក់ការ

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានទីស្នាក់ការកណ្តាលតាំងនៅខេត្តកណ្តាល និងអាច

មានទីស្នាក់ការសាខានៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមការចាំបាច់។ សមាគមអាចប្តូរទីស្នាក់ការកណ្តាល បើក បិទ ឬប្តូរទីស្នាក់ការសាខា តាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ។

**ប្រការ ៥. អំពីអត្តសញ្ញាណ**

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ គឺជាសមាគមអព្យាក្រឹត មិនស្វែងរកកម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើជាឧបករណ៍គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស គាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ ជាសមាគមដែលបម្រើផលប្រយោជន៍សមាជិក។

**ប្រការ ៦. អំពីសញ្ញាសម្គាល់**

សញ្ញាសម្គាល់របស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានភ្ជាប់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយលក្ខន្តិកៈនេះ។

**ប្រការ ៧. អំពីត្រា**

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានត្រារាងមូលពីរជាន់ទំហំ៣៤មម និងប្រើទឹកត្រាពណ៌ខៀវ មានភ្ជាប់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយលក្ខន្តិកៈនេះ។

## ជំពូកទី ៣
## សមាជិកភាព ការបាត់បង់សមាជិកភាព និងបុគ្គលិកភាព

**ប្រការ ៨. អំពីសមាជិក**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុចាប់ពី១៨ឆ្នាំឡើង មានសិទ្ធិសុំចូលជាសមាជិកបាន។ ការសុំចូលជាសមាជិកភាព ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ តាមទម្រង់ដែលបានកំណត់របស់សមាគម។

សមាជិកទាំងអស់របស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ ត្រូវគោរពច្បាប់នានាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងប្រតិបត្តិតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់សមាគម។

**ប្រការ ៩. អំពីសមាជិកភាព**

សមាជិករបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានបួនប្រភេទគឺ:

**ក-សមាជិកស្ថាបនិក** គឺជាជនទាំងឡាយណា ដែលបានលះបង់កម្លាំងកាយចិត្ត សម្ភារៈ និងថវិកាក្នុងការបង្កើតសមាគមនេះឡើង។

**ខ-សមាជិកសកម្ម** គឺជាជនទាំងឡាយណា ដែលបានចូលរួមយ៉ាងសកម្មគ្រប់សកម្មភាពរបស់សមាគម ក្នុងនោះមានដូចជាការពិភាក្សា ផ្តល់នូវបទពិសោធន៍រាល់កិច្ចការ និងសំណូមពរផ្សេងៗរបស់សមាគម។

**គ-សមាជិកកិត្តិយស** គឺជាសប្បុរសជនទាំងឡាយណាដែលបានចូលរួមផ្តល់ជាគំនិតយោបល់ ជួយជ្រោមជ្រែងដល់សមាគមនេះដើម្បីបានបង្កើត និងដំណើរការដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន។

**ឃ-សមាជិកគាំទ្រ** គឺជាអ្នកដែលផ្តល់នូវប្រភពធនធាន មានដូចជា សម្ភារៈ ថវិកា និងស្មារតី នៃការគាំទ្រឱ្យសមាគមមានដំណើរការ។

**ប្រការ ១០. អំពីការជ្រើសរើសបុគ្គលិក**

សមាគមមិនពឹងផ្អែកទៅលើសមាជិកភាពទាំងស្រុងឡើយ។ សមាគមអាចជ្រើសរើសបុគ្គលិកមួយចំនួនសម្រាប់មកបម្រើការងារ តាមគម្រោងកម្មវិធីការងារ ឬតាមកិច្ចសន្យាការងារដែលមានរយៈពេលជាក់លាក់ ដោយអនុលោមទាំងស្រុងតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១១. អំពីតួនាទី ភារកិច្ចរបស់សមាជិក និងបុគ្គលិក**

សមាជិក និងបុគ្គលិកសមាគម ត្រូវគោរព និងអនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទបញ្ជានានារបស់សមាគម។ គ្មានសមាជិក ឬបុគ្គលិកណាម្នាក់យកឈ្មោះសមាគមទៅបម្រើផលប្រយោជន៍បុគ្គល ផលប្រយោជន៍គណបក្សនយោបាយណាមួយឡើយ។

**ប្រការ ១២. អំពីការបាត់បង់សមាជិកភាព និងបុគ្គលិកភាព**

ការបាត់បង់សមាជិកភាព និងបុគ្គលិកភាពសមាគមអាចមានរូបភាពដូចខាងក្រោម៖

- ទទួលមរណភាព ឬចប់កិច្ចសន្យាការងារ
- ដាក់ពាក្យជាលាយលក្ខណ៍អក្សរជូនប្រធានគណៈកម្មការប្រតិបត្តិឱ្យបាន១៥ថ្ងៃមុនឈប់ពីការងារ
- មិនគោរពតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់សមាគម ហើយត្រូវបានបណ្តេញ ចេញដោយសេចក្តីសម្រេចរបស់គណៈកម្មការប្រតិបត្តិ តាមសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០% បូក ១ នៃសមាជិកគណៈកម្មការប្រតិបត្តិ បន្ទាប់ពីបានទទួលការណែនាំពីប្រធានសមាគមចំនួន២ដង រួចហើយនៅតែពុំព្រមកែខ្លួន។
- ជាប់ពិរុទ្ធបទល្មើសមជ្ឈិម ឬបទល្មើសព្រហ្មទណ្ឌដែលចេញសាលក្រម ឬសាលដីកាស្ថាពរពីតុលាការក្នុងព្រះរាជាណាចក្រកម្ពុជា
- មានជំងឺវិបល្លាស់ដែលមានលិខិតបញ្ជាក់ពីមន្ទីរពេទ្យស្របច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា

**ប្រការ ១៣. អំពីការបញ្ឈប់ និងការជ្រើសរើសសមាជិក និងបុគ្គលិក**

ករណីបញ្ឈប់សមាជិក ឬបុគ្គលិកណាមួយ គណៈកម្មការប្រតិបត្តិ ត្រូវប្រជុំជ្រើសរើសអ្នកថ្មីមកជំនួស ដោយផ្អែកលើគោលការណ៍កំណត់ក្នុងការជ្រើសរើសសមាជិក ឬបុគ្គលិករបស់សមាគម។

## ជំពូកទី ៤
## រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ ១៤. អំពីរចនាសម្ព័ន្ធ**

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម ៖

- សន្និបាត
- គណៈកម្មការប្រតិបត្តិ។

**ប្រការ ១៥. អំពីសន្និបាត**

**សន្និបាត** គឺជាកិច្ចប្រជុំកំពូលរបស់សមាគម។ សន្និបាតមានពីរប្រភេទ គឺសន្និបាតសាមញ្ញ និងសន្និបាតវិសាមញ្ញ។

**ប្រការ១៦. អំពីសន្និបាតសាមញ្ញ**

**សន្និបាតសាមញ្ញ** អាចត្រូវបានរៀបចំធ្វើឡើងមួយដងក្នុងមួយឆ្នាំ ដោយមានការចូលរួមពីសមាជិកសមាគមទាំងអស់។ មានតែសមាជិកគណៈកម្មការប្រតិបត្តិប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តណាមួយនៅក្នុងអង្គសន្និបាត។ នីតិវិធី របៀបវារៈ ពេលវេលា និងទីកន្លែងជាសមត្ថកិច្ចរបស់ប្រធានសន្និបាត។ ការអញ្ជើញសមាជិកចូលរួមសន្និបាតត្រូវធ្វើឡើង ឱ្យបានយ៉ាងតិច១៥ថ្ងៃ មុនថ្ងៃប្រារព្ធធ្វើសន្និបាត ដោយមានភ្ជាប់នូវរបៀបវារៈនៃកិច្ចប្រជុំ។

**ភារកិច្ចសន្និបាតសាមញ្ញគឺ ៖**

- ពិនិត្យ អនុម័តសមាសភាពគណៈកម្មការប្រតិបត្តិពេលចប់អាណត្តិ
- បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងវាយតម្លៃលើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានអនុវត្តឆ្នាំកន្លងមក
- ពិនិត្យ អនុម័តលើគោលការណ៍ ទិសដៅសកម្មភាពការងារ និងថវិកាសម្រាប់អនុវត្តបន្ត
- ពិនិត្យ អនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង។

**ប្រការ ១៧. អំពីសន្និបាតវិសាមញ្ញ**

ក្នុងករណីចាំបាច់ ឬបន្ទាន់ដែលទាក់ទងនឹងផលប្រយោជន៍រួមរបស់សមាគម សន្និបាតវិសាមញ្ញអាចដំណើរការបានគ្រប់ពេលវេលា តាមការកោះអញ្ជើញរបស់ប្រធានសមាគម ឬតាមសំណើ ៣/៤ នៃសមាជិកគណៈកម្មការប្រតិបត្តិ។

**ភារកិច្ចរបស់សន្និបាតវិសាមញ្ញ ៖**

- ពិនិត្យអនុម័តសមាសភាពគណៈកម្មការប្រតិបត្តិ ក្នុងករណីចាំបាច់
- ពិនិត្យអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ពិនិត្យអនុម័តលើការរំលាយ និងការចាត់ចែងទ្រព្យសម្បត្តិរបស់សមាគម
- ពិនិត្យអនុម័តដោះស្រាយការងារនានាដែលចាំបាច់។

**ប្រការ ១៨. អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់សន្និបាតទាំងពីរប្រភេទ មានតម្លៃគតិយុត្តបាន លុះត្រាតែមានការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត៥០% បូក ១ លើកូរ៉ុមចូលរួមក្នុងសន្និបាតយ៉ាងហោចណាស់ ៣/៤ នៃសមាជិកគណៈកម្មការប្រតិបត្តិ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានសន្និបាតមានឧត្តមានុភាព។ ប្រធានសន្និបាត អាចជាប្រធានសមាគម ឬតាមការជ្រើសរើសរបស់អង្គសន្និបាត។

**ប្រការ ១៩. អំពីគណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិ គឺជាស្ថាប័នដឹកនាំការងារប្រចាំថ្ងៃទាំងមូលរបស់សមាគម ស្របតាមគោល-ការណ៍ នៃសេចក្តីសម្រេចរបស់សន្និបាត។

**ប្រការ ២០. អំពីសមាជិកគណៈកម្មការប្រតិបត្តិ**

គណៈកម្មការប្រតិបត្តិ មានសមាសភាពយ៉ាងតិចចំនួន ៥ (ប្រាំ)រូប ដោយអនុលោមតាមការសម្រេចចិត្តរបស់សន្និបាត។ គណៈកម្មការប្រតិបត្តិមានអាណត្តិ៥(ប្រាំ)ឆ្នាំ ហើយអាចឈរឈ្មោះនៅអាណត្តិក្រោយទៀតបាន។ សមាសភាពគណៈកម្មការប្រតិបត្តិមានដូចខាងក្រោម៖

- ប្រធាន ១រូប
- អនុប្រធាន ២រូប
- រដ្ឋបាល/ហេរញ្ញិក ១រូប
- ប្រធានកម្មវិធី ១រូប។

**ប្រការ ២១. អំពីតួនាទីសមាជិកគណៈកម្មការប្រតិបត្តិ**

**ក. អំពីប្រធានគណៈកម្មការប្រតិបត្តិ**

ប្រធានគណៈកម្មការប្រតិបត្តិ គឺជាប្រធានសមាគម ដែលជាតំណាងស្របច្បាប់ និងមានតួនាទីទទួលខុសត្រូវរួមចំពោះសកម្មភាពការងាររបស់សមាគម។

**ខ. អំពីអនុប្រធានគណៈកម្មការប្រតិបត្តិ**

សមាគមមានអនុប្រធានចំនួន២ រូបក្នុងការគាំទ្រ និងជួយដឹកនាំការងារក្នុងសមាគម។ អនុប្រធានមានតួនាទីជាប្រធានស្តីទីក្នុងករណីប្រធានផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ និងទទួលខុសត្រូវរាល់ការងារដែលប្រធានប្រគល់ឱ្យ។

**គ. អំពីរដ្ឋបាល/ហេរញ្ញិក**

រដ្ឋបាល/ហេរញ្ញិកមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង រៀបចំរាល់ការងាររដ្ឋបាល ទ្រព្យសម្បត្តិ សារពើភណ្ឌរបស់សមាគម
- រៀបចំរបាយការណ៍ការងារ លិខិត ឯកសារផ្សេងៗ ព្រមទាំងរក្សា និងតម្កល់ឯកសារ
- គ្រប់គ្រងបុគ្គលិក និងសម្ភារៈការិយាល័យ
- ធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំនានា និងអង្គសន្និបាតរបស់សមាគម
- រៀបចំនីតិវិធី របៀបវារៈ ពេលវេលា និងទីកន្លែងសម្រាប់ប្រជុំ និងអង្គសន្និបាត
- ទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការគ្រប់គ្រងនិងត្រួតពិនិត្យថវិកា បញ្ជីចំណូល-ចំណាយនានា
- ធ្វើគម្រោងថវិកាប្រចាំឆ្នាំដើម្បីដាក់ជូនគណៈកម្មការប្រតិបត្តិពិនិត្យ សម្រេច។
- ជាភាគីចុះហត្ថលេខាជាមួយប្រធានសមាគមលើប្រតិបត្តិការចំណូល និងចំណាយ ព្រមទាំងប្រតិបត្តិការគណនេយ្យនៅធនាគាររបស់សមាគម
- ទទួលរាល់កិច្ចការដែលប្រធានសមាគមប្រគល់ឱ្យ។

**ឃ.អំពីប្រធានកម្មវិធី**

ប្រធានកម្មវិធីមានភារកិច្ចរៀបចំផែនការគម្រោងសកម្មភាពការងារ និងអនុវត្តកម្មវិធីរបស់សមាគមស្របតាមសេចក្តីសម្រេចរបស់គណៈកម្មការប្រតិបត្តិ។

**ប្រការ ២២. អំពីកិច្ចប្រជុំ**

គណៈកម្មការប្រតិបត្តិអាចជួបប្រជុំគ្នារៀងរាល់៣(បី)ខែម្តង ឬនៅពេលណាក៏បាន ដោយប្រធានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរយ៉ាងហោចណាស់៣ថ្ងៃមុន ដោយមានភ្ជាប់មកជាមួយនូវកាលបរិច្ឆេទ និងរបៀបវារៈនៃកិច្ចប្រជុំ។ ក្នុងករណីចាំបាច់គណៈកម្មការប្រតិបត្តិអាចកោះប្រជុំវិសាមញ្ញបាន តាមការកោះអញ្ជើញរបស់ប្រធានសមាគម ឬតាមសំណើយ៉ាងតិច ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិ។

**ប្រការ ២៣. អំពីលក្ខណៈគតិយុត្ត**

សេចក្តីសម្រេចរបស់កិច្ចប្រជុំគណៈកម្មការប្រតិបត្តិទាំងពីរប្រភេទ មានលក្ខណៈគតិយុត្តបានតាមការអនុម័តដោយសំឡេងគាំទ្រ៥០% បូក ១ លើកូរ៉ុមចូលរួមយ៉ាងតិច ២/៣ នៃសមាជិកគណៈកម្មការប្រតិបត្តិ។

## ជំពូកទី ៥

## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬធ្វើវិសោធនកម្មលក្ខន្តិកៈ

**ប្រការ ២៤. អំពីការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬធ្វើវិសោធនកម្មលក្ខន្តិកៈ**

ការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬធ្វើវិសោធនកម្មលក្ខន្តិកៈ អាចធ្វើបានតាមសំណើសុំរបស់ប្រធាន ឬតាមសំណូមពរ ៣/៤ នៃសមាជិកគណៈកម្មការប្រតិបត្តិ។ រាល់ការអនុម័តក្នុងការផ្លាស់ប្តូរជាសមត្ថកិច្ចរបស់សន្និបាត។

លក្ខន្តិកៈ ស.អ

## ជំពូកទី ៦
## ប្រភពធនធាន និងទ្រព្យសម្បត្តិ

**ប្រការ២៥. អំពីប្រភពធនធាន និងទ្រព្យសម្បត្តិ**

- ភាគទាន ឬវិភាគទាន ឬបរិសទានរបស់សមាជិក
- ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម
- អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល
- ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

## ជំពូកទី ៧
## វិធាននៃការគ្រប់គ្រងប្រភពធនធាន និងទ្រព្យសម្បត្តិ

**ប្រការ ២៦. អំពីការគ្រប់គ្រងប្រភពធនធាន និងទ្រព្យសម្បត្តិ**

រាល់ចំណូលរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ ត្រូវគ្រប់គ្រងដោយរដ្ឋបាល/ហេរញ្ញិក ដោយមានចុះហត្ថលេខាយល់ព្រមពីប្រធានសមាគម។ ចំណូលជាសាច់ប្រាក់ ឬមូលប្បទានប័ត្រ ត្រូវបញ្ចូលក្នុងគណនីធនាគារស្របច្បាប់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងនាមសមាគម តាមការសម្រេចរបស់គណៈកម្មការប្រតិបត្តិ។ ថវិកាអាចរក្សាទុកមួយចំនួនក្នុងបេឡាសម្រាប់ប្រើប្រាស់ចាំបាច់ក្នុងសមាគម តាមការកំណត់របស់គណៈកម្មការប្រតិបត្តិ។

## ជំពូកទី ៨
## វិធាននៃការផ្អាកសកម្មភាព ការរំលាយ ឬចាត់ចែងធនធាន និងទ្រព្យសម្បត្តិ នៅពេលដែលត្រូវរំលាយ

**ប្រការ ២៧. អំពីវិធាននៃការផ្អាកសកម្មភាព**

មានតែសន្និបាតមួយគត់ដែលអាចសម្រេចផ្អាកសកម្មភាពសមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ។ នៅមុនពេលសមាគមត្រូវបានផ្អាកសកម្មភាព សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់សមាគម។

**ប្រការ ២៨. អំពីវិធាននៃការរំលាយ**

មានតែសន្និបាតមួយគត់ ដែលអាចសម្រេចរំលាយសមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ នៅពេលត្រូវបានរំលាយ សន្និបាតត្រូវរៀបចំបង្កើតគណៈកម្មការមួយដើម្បីជម្រះបញ្ជីរបស់សមាគម។

**ប្រការ ២៩. អំពីវិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ**

រាល់ទ្រព្យសម្បត្តិរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ ដែលសល់ក្រោយពីជម្រះបំណុលស្របច្បាប់រួច ត្រូវប្រគល់ឱ្យអង្គការ ឬសមាគម ដែលមានគោលបំណងដូចសមាគមនេះ ឬតាមការសម្រេចរបស់អង្គសន្និបាត។ សមាជិក និងបុគ្គលិកទាំងអស់ក៏ត្រូវរំសាយផងដែរ នៅពេលដែលសមាគមត្រូវបានរំលាយ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ ៣០.**

រាល់បទប្បញ្ញត្តិរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ ទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារ

ស.អ

នៃលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣១.**

រាល់ការធ្វើសកម្មភាពរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ ត្រូវអនុវត្តតាមលក្ខន្តិកៈដូចដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ ៣២.**

លក្ខន្តិកៈរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ មានសុពលភាពគតិយុត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តកណ្តាល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ខៀវ មាលី**

**បានតម្កល់ទុកលក្ខន្តិកៈ**

របស់

សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ

ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ តាមប្រកាស

លេខ: ៦០៤៩ ប្រ.ក ចុះថ្ងៃទី២៨ខែធ្នូ ឆ្នាំ ២០៧៣។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០២៣

នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ

ប្រធាន

គាន ណារិន

លក្ខន្តិកៈ

ស.អ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធ

## រចនាសម្ព័ន្ធរបស់

## សមាគមសុខខៀវ សមិទ្ធិ ដើម្បីសិល្បៈ

SOK KHIEU SAMITHI'S ART ASSOCIATION




ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តកណ្ដាល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

**ជ.គណៈកម្មការប្រតិបត្តិ**

**ប្រធាន**

**ខៀវ មាលី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធ
## សមាសភាពថ្នាក់ដឹកនាំរបស់សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ

| ល.រ | គោត្តនាម និងនាម | ភេទ | មុខតំណែង | ផ្សេងៗ |
|---|---|---|---|---|
| | **សមាសភាពគណៈកម្មការប្រតិបត្តិ** | | | |
| ១ | លោកជំទាវ ខៀវ មាលី | ស្រី | ប្រធាន | |
| ២ | ឯកឧត្តមបណ្ឌិតសាស្ត្រាចារ្យ សុក ស៊ីផាន់ណា | ប្រុស | អនុប្រធាន | |
| ៣ | ឯកឧត្តមបណ្ឌិត ឆែម គាតរិទ្ធី | ប្រុស | អនុប្រធាន | |
| ៤ | កញ្ញា សុក ខៀវរ៉ូហ្សេត | ស្រី | រដ្ឋបាល/ហេរញ្ញិក | |
| ៥ | លោក វ៉េនដល នីកកូលេស | ប្រុស | ប្រធានកម្មវិធី | |

លក្ខន្តិកៈ
ស.អ

ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តកណ្ដាល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣
**ជ.គណៈកម្មការប្រតិបត្តិ**
**ប្រធាន**

**ខៀវ មាលី**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធ
## សញ្ញាសម្គាល់ និងត្រា
## សមាគមសុកខៀវ សមិទ្ធិ ដើម្បីសិល្បៈ
SOK KHIEU SAMITHI'S ART ASSOCIATION

### ១. អំពីសញ្ញាសម្គាល់

### ២. អំពីត្រា

ថ្ងៃពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តកណ្តាល ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣
**ជ.គណៈកម្មការប្រតិបត្តិ**
**ប្រធាន**

**ខៀវ មាលី**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

នាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ

ការិយាល័យកិច្ចការសមាគម

## <u>លិខិតប្រគល់-ទទួល</u>

បានប្រគល់ជូនសមាគមសុករខៀវ សមិទ្ធិ ដើម្បីសិល្បៈ ចុះឡើងវិញ នូវឯកសាមួយចំនួនរួមមាន៖

- ✓ ប្រកាសលេខ ៦០៤៩ ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ ចំនួន ០៣ច្បាប់
- ✓ លក្ខន្តិកៈ ចំនួន ០១ច្បាប់
- ✓ របនាសម្ព័ន្ធ ចំនួន ០១ច្បាប់
- ✓ សញ្ញាសម្គាល់ និងត្រា ចំនួន ០១ច្បាប់
- ✓ ឧបសម្ព័ន្ធសមាសភាពថ្នាក់ដឹកនាំ ចំនួន ០១ច្បាប់
- ✓ ប្រវត្តិរូបស្ថាបនិក ចំនួន ០១ច្បាប់។

*** <u>កំណត់សម្គាល់</u>៖ អនុលោមតាមកថាខណ្ឌទី១ មាត្រា១០ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក <u>ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីព័ត៌មានរាល់គណនី ដែលត្រូវប្រើបើកសម្រាប់កិច្ចសហប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាជូនមកក្រសួងមហាផ្ទៃ និងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ</u> គិតចាប់ពីថ្ងៃដែលបានចុះបញ្ជី។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០២៤

អ្នកទទួល អ្នកប្រគល់